MOSALVY

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២

លេខ ២០៥ ស.ក.ប.យ.

# ប្រកាស

## ស្តីពី

## ការផ្ទេរ ប្តូរឈ្មោះ និងបង្កើតការិយាល័យ

## ចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ

✻✻✻✻✻៙✻៚✻✻✻✻✻

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិ ទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកត/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- បានឃើញ អនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ៦៤០ សកអ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន
- បានឃើញប្រកាសលេខ ៣៩០ ស.ក.ប.យ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ៣៨៩ ស.ក.ប.យ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ៈ** ត្រូវបានប្តូរឈ្មោះ និងផ្ទេរការិយាល័យចំនួន ០៣ អោយស្ថិតនៅក្នុងការគ្រប់គ្រង របស់នាយកដ្ឋាន សហប្រតិបត្តិការ អន្តរជាតិ និងជំនួយ នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ដូចតទៅ ៖

១-ត្រូវបានប្តូរឈ្មោះ ការិយាល័យទំនាក់ទំនងអន្តរជាតិ មកជាការិយាល័យ អន្តរជាតិ និងជំនួយ

២-ផ្ទេរការិយាល័យអាស៊ានបច្ចុប្បន្ន ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ របស់ប្រធានស្ថាប័ន មកស្ថិតក្រោមការគ្រប់គ្រង របស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ នៃអគ្គនាយកដ្ឋានកិច្ចការ រដ្ឋបាល និងហិរញ្ញវត្ថុវិញ។

៣-ផ្ទេរការិយាល័យពិធីការ និងមន្ត្រីរាជការបច្ចុប្បន្ន ក្រោមការគ្រប់គ្រងរបស់ ខុទ្ទកាល័យ មកស្ថិតក្រោមការគ្រប់គ្រង របស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ នៃអគ្គនាយកដ្ឋាន កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុវិញ។

**ប្រការ២ៈ** បង្កើតការិយាល័យ សហប្រតិបត្តិការ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ និងជំនួយ។

**ប្រការ៣ៈ** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋាន កិច្ចការ រដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ និងជំនួយ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ និងស្ថាប័ន អង្គភាពពាក់ព័ន្ធ មានការកិច្ច រៀងៗខ្លួនអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់អង្គភាពចំនុះក្រសួង "ដើម្បីជូនជ្រាប"
- ដូចមានក្នុងប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ